មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ ២០២១

| | |
|---|---|
| ឈ្មោះស្ថាប័ន | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") |
| គោលដៅ | ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឃើញប្រទេសកម្ពុជាមានសន្តិភាពដែលពលរដ្ឋគ្រប់រូបអាចអនុវត្តសិទ្ធិមនុស្សមូលដ្ឋានដែលខ្លួនមានពីកំណើត ទទួលបាននីតិរដ្ឋដោយគ្មាននិទណ្ឌភាព ទទួលបានការគោរពស្មើភាពគ្នាដោយគ្មានការរើសអើង ទទួលបានការពង្រឹងភាពអង់អាចក្លាហានដើម្បីចូលរួមយ៉ាងពេញលេញក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ ព្រមទាំងទទួលបានចំណែកនៃអត្ថប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពរបស់ប្រទេសកម្ពុជា។ |
| រយៈពេល | ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០២១ |

ក្នុងអំឡុងពេលពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២១ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បានអនុវត្តសកម្មភាពការងាររបស់ខ្លួនដូចមានរៀបរាប់ខាងក្រោម ៖

## ១. សកម្មភាពការងារសំខាន់ដែលសម្រេចបានក្នុងឆ្នាំ២០២១

### *ការចេញឯកសារផ្សព្វផ្សាយ*

នៅក្នុងឆ្នាំ២០២១ នេះ ម.ស.ម.ក បានចេញឯកសារផ្សព្វផ្សាយចំនួន ៩៧ ឯកសារដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្សក្នុងនោះរួមមានសេចក្តីថ្លែងការណ៍ លិខិតចំហ សេចក្តីថ្លែងការណ៍រួម សេចក្តីប្រកាសព័ត៌មានបន្ទាន់អំពីអ្នកការពារសិទ្ធិមនុស្ស កំណត់ត្រាសង្ខេប របាយការណ៍ស្រាវជ្រាវ សលាកបត្រព័ត៌មាន អប់រំសិទ្ធិមនុស្សអនឡាញ សៀវភៅមេរៀន ប័ណ្ណព័ត៌មាន ខិតប័ណ្ណព័ត៌មាន និង វីដេអូជាដើម។ ឯកសារទាំងនេះចេញផ្សាយក្នុងគោលបំណងតស៊ូមតិ យុទ្ធនាការលើកស្ទួយការគោរពសិទ្ធិមនុស្ស និងអប់រំផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងអំពីបញ្ហាសិទ្ធិមនុស្សរួមមានសេរីភាពមូលដ្ឋាន សិទ្ធិដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ការបង្ហាញទំនោរយេនឌ័រនិងលក្ខណៈភេទ សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា សិទ្ធិស្ត្រី សិទ្ធិជំនុំជម្រះដោយយុត្តិធម៌និងសិទ្ធិជនជាតិដើមភាគតិចជាដើម។ ឧទាហរណ៍ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ ម.ស.ម.ក បានប្រកាសផ្សព្វផ្សាយជាផ្លូវការអំពីវេទិកាអប់រំសិទ្ធិមនុស្សស្តីពីសេរីភាពខាងការបញ្ចេញមតិ ដែល

រួមមានមេរៀនអនឡាញចំនួនបីគឺ១) សេរីភាពខាងការបញ្ចេញមតិ ២) សិទ្ធិទទួលព័ត៌មាន និង៣) ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ដែលក្នុងនោះមានដូចជា មេរៀន វីដេអូតុក្កតា ប័ណ្ណព័ត៌មាន និងសំណួរសាកល្បង ដែលមានទាំងភាសាខ្មែរ និងអង់គ្លេស។

ក្នុងចំណោមការចេញផ្សាយចំនួន៩៧ឯកសារ មាន ១១ឯកសារគឺជាវីដេអូដែលម.ស.ម.កបានផលិតឡើងសម្រាប់ការអប់រំផ្សព្វផ្សាយដូចជា៖

| លរ | កាលបរិច្ឆេទ | ចំណងជើង |
|---|---|---|
| ១ | ០៣ ឧសភា ២០២១ | ការរើសអើងនៅកន្លែងការងារសម្រាប់អ្នកប្តូរយេនឌ័រ |
| ២ | ២៥ ឧសភា ២០២១ | អ្នកស្រឡាញ់ភេទដូចគ្នា និងក្តីសង្ឃឹម |
| ៣ | ១៤ កក្កដា ២០២១ | សេរីភាពខ្ញុំ! មតិខ្ញុំ! |
| ៤ | ១៥ កក្កដា ២០២១ | ស្វែងរកព័ត៌មានគ្មានកំហុស |
| ៥ | ១៦ កក្កដា ២០២១ | ព័ត៌មានដែលអាចទុកចិត្តបាន |
| ៦ | ១៥ កញ្ញា ២០២១ | ទិវាប្រជាធិបតេយ្យអន្តរជាតិ |
| ៧ | ២៣ កញ្ញា ២០២១ | ដុំពកខ្មៅ |
| ៨ | ០៤ វិច្ឆិកា ២០២១ | អ្នកបន្តវេន |
| ៩ | ០៩ ធ្នូ ២០២១ | ចូលរួមទាំងអស់គ្នាដើម្បីជំរុញការគោរពសិទ្ធិមនុស្ស |
| ១០ | ១០ ធ្នូ ២០២១ | ខ្ញុំគាំទ្រអ្នកការពារសិទ្ធិមនុស្សជាស្ត្រី! ចុះអ្នកវិញ? |
| ១១ | ១០ ធ្នូ ២០២១ | សិទ្ធិមនុស្សជាអ្វី? |

សាធារណជនអ្នកអាចទស្សនាវីដេអូទាំងនេះនៅលើបណ្តាញសង្គមយូធូបនិងទំព័រហ្វេសប៊ុក របស់ម.ស.ម.ក។

## *ការឃ្លាំមើលនិងសង្កេតការណ៍សវនាការ*

ម.ស.ម.ក បានបន្តតាមដានអត្ថបទចេញផ្សាយតាមសារព័ត៌មាននានាក្នុងគោលបំណងទទួលបានព័ត៌មានទាន់ហេតុការណ៍ជុំវិញព្រឹត្តិការណ៍នានានិងបញ្ហាសំខាន់ៗមួយចំនួនដែលផ្តោតទៅលើសិទ្ធិសេរីភាពមូលដ្ឋាន សិទ្ធិដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា សិទ្ធិស្ត្រី និងស្ថានភាពសិទ្ធិមនុស្សដទៃទៀតនៅទូទាំងប្រទេស។ ជាសរុបក្នុងរយៈពេលនៃរបាយការណ៍នេះ ម.ស.ម.ក បានប្រមូលព័ត៌មានចំនួន ១៤៦២ អត្ថបទដែលចេញផ្សាយតាមសារព័ត៌មានពាក់ព័ន្ធនឹងសិទ្ធិសេរីភាពមូលដ្ឋាន សេរីភាពខាងការជួបប្រជុំ សេរីភាពខាងការបញ្ចេញមតិ សិទ្ធិដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានិងសិទ្ធិស្ត្រីជាដើម។

ម្យ៉ាងទៀត ជាផ្នែកនៃគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងឆ្នាំ២០២១ ម.ស.ម.ក បានសង្កេតការណ៍សវនាការក្នុងករណីព្រហ្មទណ្ឌចំនួន៨៥ ករណីនៅសាលាឧទ្ធរណ៍ និងករណីពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រចំនួន១៩ ករណីនៅសាលាដំបូងខេត្តកំពង់ចាម និងខេត្តសៀមរាប។ លទ្ធផលនៃ

ការសង្កេតការណ៍សវនាការនេះ គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌បានចេញផ្សាយព្រឹត្តិបត្រព័ត៌មានចំនួនបី និងរបាយការណ៍ស្រាវជ្រាវប្រចាំឆ្នាំចំនួន១ ដូចខាងក្រោម៖

1. សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ និងការពន្យល់ប្រាប់សិទ្ធិដល់ជនជាប់ចោទជាស្ត្រី
2. សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស
3. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទជាអនីតិជន
4. របាយការណ៍ប្រចាំឆ្នាំស្តីពី សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជាការសង្កេតការណ៍នៅសាលាឧទ្ធរណ៍របាយការណ៍ប្រចាំឆ្នាំ (ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០) ដែលមានបញ្ចូលនូវអនុសាសន៍មួយចំនួនទាក់ទងនឹងការពង្រឹងនីតិរដ្ឋ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងច្បាប់នៅកម្ពុជា។

ម.ស.ម.ក បានចេញផ្សាយខិត្តប័ណ្ណព័ត៌មានមួយចំនួនផ្សេងទៀតផងដែរទាក់ទិននឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ សិទ្ធិស្ត្រី សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ សិទ្ធិសេរីភាពមូលដ្ឋាន ធុរកិច្ចនិងសិទ្ធិមនុស្សជាដើម។

## *យុទ្ធនាការ*

- *ទិវានារីអន្តរជាតិ ខែមីនា ឆ្នាំ២០២១*

នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ ម.ស.ម.ក បានរៀបចំកម្មវិធីអបអរសាទរទិវានារីអន្តរជាតិ។ ទិវានេះរៀបចំឡើងក្រោមប្រធានបទ "ខ្ញុំស៊ូជម្នះនឹងវិសមភាពយេនឌ័រ" នៅការិយាល័យម.ស.ម.ក នារាជធានីភ្នំពេញដោយមានការផ្សាយផ្ទាល់តាមរយៈគេហទំព័រហ្វេសបុករបស់ម.ស.ម.ក ផងដែរ។ ទិវានេះរៀបចំឡើងក្នុងគោលបំណង៖ ១) លើកកម្ពស់ការយល់ដឹងក្នុងចំណោមសាធារណៈជនអំពីការចូលរួមរបស់ស្ត្រីនៅក្នុងសង្គមស៊ីវិលនិងការងាររបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី និង២)បង្ហាញពីបញ្ហាប្រឈមដែលស្ត្រីចូលរួមនៅក្នុងសង្គមឬការចូលរួមជាសាធារណៈនៅក្នុងប្រទេសកម្ពុជា។ កម្មវិធីនេះប្រព្រឹត្តិទៅដោយមានរបៀបវារៈបីសំខាន់ៗគឺ កិច្ចពិភាក្សាក្នុងចំណោមស្ត្រីដែលមានប្រវត្តិការងារជាអ្នកសារព័ត៌មាន និងសកម្មនិយមក្នុងវិស័យសិទ្ធិមនុស្សដើម្បីបន្លឺសំឡេងរបស់ពួកគាត់ពាក់ព័ន្ធនឹងការប្រឈមនិងការងាររបស់ពួកគាត់។ បន្ទាប់មកមានការសំដែងក្នុងទម្រង់ល្ខោនជីវិតដែលសំដែងចេញជាឈុតឆាកលើកយកបញ្ហាជាចំណោទ ហើយឲ្យអ្នកទស្សនាចូលរួមស្វែងរកដំណោះស្រាយចំពោះបញ្ហានោះ។ បន្ថែមពីនេះក៏មានកម្មវិធីសំណួរចម្លើយដើម្បីយករង្វានពាក់ព័ន្ធនឹងសិទ្ធិស្ត្រី ដោយមានអ្នកចូលរួមឆ្លើយសំណួរត្រូវចំនួន១៨ នាក់ដែលត្រូវបានរង្វាន់អនុស្សាវរីយ៍ពីម.ស.ម.ក ។ កម្មវិធីចុងក្រោយគឺការសំដែងចម្រៀងចាប៉ីដងវែង។

- *យុទ្ធនាការ១៦ ថ្ងៃដើម្បីបញ្ចប់អំពើហិង្សាទាក់ទងនឹងយេនឌ័រនិងទិវាសិទ្ធិមនុស្សអន្តរជាតិ*

ចាប់ពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ ដល់ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ គឺជាយុទ្ធនាការ១៦ ថ្ងៃដើម្បីបញ្ចប់អំពើហិង្សាទាក់ទងនឹងយេនឌ័រក្រោមប្រធានបទ «ចូលរួមទាំងអស់គ្នាដើម្បីជំរុញការគោរពសិទ្ធិមនុស្ស» ដែលបានប្រព្រឹត្តទៅចាប់តាំងពីទិវាអន្តរជាតិដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី រហូតដល់ទិវាសិទ្ធិមនុស្សអន្តរជាតិ។ យុទ្ធនាការ១៦ ថ្ងៃនេះមានគោលបំណងផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងដើម្បីបង្កើតលម្ហសម្រាប់ស្ត្រីមកពីវិស័យផ្សេងៗធ្វើការសម្តែង និងតស៊ូមតិដើម្បីបញ្ចប់អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅកម្ពុជា។

នៅឆ្នាំ២០២១ ម.ស.ម.ក បានរៀបចំសកម្មភាពជាច្រើនជាបន្តបន្ទាប់ដើម្បីលើកកម្ពស់ការយល់ដឹងអំពីស្ថានភាពសិទ្ធិមនុស្ស ជាពិសេសពាក់ព័ន្ធនឹងសិទ្ធិស្ត្រីនិងកិច្ចខិតខំប្រឹងប្រែងរបស់សង្គមស៊ីវិលនិងនិងអ្នកការពារសិទ្ធិមនុស្សក្នុងការការពារនិងលើកស្ទួយសិទ្ធិមនុស្សនិងសេរីភាពមូលដ្ឋាននៅកម្ពុជា។

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ២៤ វិច្ឆិកា ២០២១ | សេចក្តីថ្លែងការណ៍ផ្សព្វផ្សាយអំពីយុទ្ធនាការជាភាសាខ្មែរ និងអង់គ្លេស។ |
| ២ | ២៤ វិច្ឆិកា ២០២១ | ខិត្តប័ណ្ណព័ត៌មានអំពីកាលប្បវត្តិស្ត្រីថ្ងៃសុក្រឆ្នាំ២០២០ ២០២១ |
| ៣ | ២៥ វិច្ឆិកា ២០២១ | កម្មវិធីវិទ្យុ |
| ៤ | ២៩ វិច្ឆិកា ២០២១ | វីដេអូខ្លីសំដែងនូវសារលើកទឹកចិត្តដល់អ្នកការពារសិទ្ធិមនុស្សស្ត្រី "ខ្ញុំគាំទ្រអ្នកការពារសិទ្ធិមនុស្សជាស្ត្រី! ចុះអ្នកវិញ? |
| ៥ | ២៨ វិច្ឆិកា ២០២១ | ការចេញផ្សាយសៀវភៅកម្រងជីវប្រវត្តរបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រីនិងអ្នកស្រឡាញ់ភេទដូចគ្នា។ |
| ៦ | ០១ ធ្នូ ២០២១ | ការផ្សព្វផ្សាយខិតបណ្ណព័ត៌មានអំពីការចូលរួមការប្រកួតប្រជែងឆ្លើយសំណួរយករង្វាន់លើទំព័រហ្វេសប៊ុក។ |
| ៧ | ០៩ ធ្នូ ២០២១ | ការចេញផ្សាយវិដេអូអំពី ចូលរួមទាំងអស់គ្នាដើម្បីជំរុញការគោរពសិទ្ធិមនុស្ស |
| ៨ | ០៩ ធ្នូ ២០២១ | ការចេញផ្សាយរូបភាពអមជាមួយនឹងសារលើកទឹកចិត្តពីអ្នកការពារសិទ្ធិមនុស្សចំនួន ១៣ នាក់ដែលបានលះបង់ពេលវេលាផ្ទាល់ខ្លួនដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស យុត្តិធម៌សង្គម និធនធានធម្មជាតិនៅក្នុងប្រទេសកម្ពុជា។ |
| ៩ | ០៩ ធ្នូ ២០២១ | ការប្រារព្ធកម្មវិធីទិវាសិទ្ធិមនុស្សអន្តរជាតិនៅម.ស.ម.ក និងផ្សាយផ្ទាល់អនឡាញតាមហ្វេសបុក |
| ១០ | ១០ ធ្នូ ២០២១ | ការផ្សព្វផ្សាយកាលប្បវត្តិសិទ្ធិមនុស្សឆ្នាំ២០២១ នៅលើគេហទំព័រសិទ្ធិ ការបង្ហាញកាលប្បវត្តិនៃករណីរំលោភបំពានសិទ្ធិមនុស្សដែលបានកើតឡើងកាលពីឆ្នាំកន្លងទៅ។ ខិត្តប័ណ្ណព័ត៌មានចំនួន១២ ដែលបង្ហាញព្រឹត្តិការណ៍សំខាន់ៗក្នុងខែនីមួយៗក្នុងឆ្នាំ២០២១ ស្រង់ចេញពីកាលប្បវត្តិសិទ្ធិមនុស្ស។ |
| ១១ | ១០ ធ្នូ ២០២១ | ខិត្តប័ណ្ណព័ត៌មានស្តីពី ជនរងគ្រោះអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងតុលាការកម្ពុជា។ |

### *កម្មវិធីវិទ្យុ*

នៅឆ្នាំ២០២១ ម.ស.ម.ក បានផលិតកម្មវិធីផ្សាយផ្ទាល់កិច្ចពិភាក្សាតាមវិទ្យុចំនួន ១៥៩ លើកដោយផ្តោតលើប្រធានបទនានាតាមវិស័យនីមួយៗដូចមានដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ការពិភាក្សាអំពីច្បាប់និងការវិភាគប្រចាំសប្តាហ៍។ ក្នុងកម្មវិធីពិភាក្សាទាំងនោះសុទ្ធតែមានការអញ្ជើញវាគ្មិនចម្រុះដែលជាភាគីពាក់ព័ន្ធសំខាន់ៗដើម្បីចូលរួមពីអង្គការសង្គមស៊ីវិល មេធាវីនិងរដ្ឋាភិបាលដើម្បីចូលរួមចែករំលែកនូវគំនិតយោបល់ក្នុងកិច្ចពិភាក្សា។ រាល់កម្មវិធីពិភាក្សាទាំងអស់ក៏មានផ្សព្វផ្សាយបន្តផ្ទាល់នៅលើគេហទំព័រហ្វេសប៊ុករបស់ម.ស.ម.ក ផងដែរ ដែលទទួលបានព័ត៌មានចំនួន៦១៩ ០៨៤ ទទួលបានការចុច Like ចំនួន ៥៩៨៧ ចែករំលែកបន្តចំនួន ២៦៧៥ ចូលទស្សនាចំនួន ២៣៨ ៥៦៤ និងផ្តល់មតិយោបល់ចំនួន៨៩៤។

### *ការបណ្តុះបណ្តាល*

ម.ស.ម.ក បានរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល វគ្គបណ្តុះបណ្តាលតាមដានបន្ត ទាក់ទងនឹងការតស៊ូមតិ ច្បាប់ ធុរកិច្ចនិងសិទ្ធិមនុស្សចំនួន ១៩ លើក។ លើសពីនេះក៏មានកិច្ចប្រជុំផ្សេងទៀតផងដែរ រួមមានកិច្ចប្រជុំប្រចាំត្រីមាស ការប្រជុំចែករំលែកនិងការលើកកម្ពស់ការយល់ដឹងក្នុងចំណោមសហគមន៍ និងការចែករំលែកក្នុងចំណោមមេធាវី កម្មវិធីផ្សព្វផ្សាយ កម្មវិធីបទបង្ហាញសិក្ខាសលាពិគ្រោះយោបល់ ការតាំងពិពណ៌។

## ២. ការប្រឈមនិងបទពិសោធន៍

ក្នុងឆ្នាំ២០២១ ម.ស.ម.ក បានប្រឈមនឹងបញ្ហាមួយចំនួនទាំងក្នុងនិងក្រៅស្ថាប័ន។ ការប្រឈមនៅក្រៅស្ថាប័ន គឺបញ្ហារីករាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ជាលើកទី២ចាប់ពីខែមីនា រហូតដល់ ចុងឆ្នាំ២០២១ ដែលបានបង្កការលំបាកដល់ការអនុវត្តគម្រោងរបស់ ម.ស.ម.ក។ ដើម្បីសម្របទៅនឹងការរីករាលដាលនេះ ម.ស.ម.ក បានអនុវត្តនូវវប្បធម៌ធ្វើការងារបែបថ្មីមួយទាំងនៅលើអ៊ីនធឺណិត ឬការប្រាស្រ័យទាក់ទងគ្នាផ្ទាល់ អាស្រ័យទៅលើស្ថានភាពនៃមេរោគកូវីដ-១៩។ ម.ស.ម.ក បានអនុវត្តតាមសេចក្តីណែនាំរបស់រដ្ឋាភិបាលតាមរយៈការដាក់ឱ្យ អនុវត្តតាមវិធានការនានារបស់ក្រសួងសុខាភិបាលជាបន្តបន្ទាប់ ដូចជាការបិទខ្ទប់តំបន់រស់នៅ ការធ្វើការតាមអនឡាញ ការរក្សាគម្លាតបុគ្គល អនាម័យ ការកំណត់ការប្រមូលផ្តុំ និងចំនួននៃអ្នកចូលរួមជួបប្រជុំជាដើម។

ដោយសារការរីករាលដាលនេះ សកម្មភាព ឬកម្មវិធីដែលបានគ្រោងរៀបចំដោយផ្ទាល់ភាគច្រើននៅក្នុងឆ្នាំ២០២១ ត្រូវបានធ្វើនៅលើអ៊ីនធឺណិតជំនួសវិញ ដើម្បីឱ្យស្របតាមវិធានការការពារសុវត្ថិភាពដែលមានសារៈសំខាន់នានា។

## ៣. យេនឌ័រ និងគោលការណ៍ផ្អែកលើសិទ្ធិជាមូលដ្ឋាន

ម.ស.ម.ក នៅតែអនុវត្តសកម្មភាពការងាររបស់ខ្លួនដើម្បីជានាយ៉ាងណាដើម្បីឲ្យមានសមភាពយេនឌ័រ ជាពិសេសសការចូលរួមរបស់ស្ត្រី។ នៅគ្រប់ពេលទាំងអស់ ម.ស.ម.ក តែងតែលើកឡើងពីស្ថានភាពផ្លូវច្បាប់ស្មើភាពគ្នារវាងបុរស ស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នាទាក់ទងនឹងសិទ្ធិមនុស្ស។

លើសពីនោះ ម.ស.ម.ក បានរៀបចំព្រឹត្តិការណ៍សំខាន់មួយចំនួនដើម្បីលើកកម្ពស់ស្ត្រី និងសមភាពយេនឌ័រនៅក្នុងឱកាសនៃទិវានារីអន្តរជាតិ ០៨ មីនា ឆ្នាំ២០២១ យុទ្ធនាការ ១៦ ថ្ងៃដើម្បីបញ្ឈប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងនៅតែបន្តផ្តល់ជំនួយផ្នែកច្បាប់ មនុស្សធម៌ និងផ្លូវចិត្តតាមលទ្ធភាពដែលអាចធ្វើទៅបានដល់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នាដែលបានប្រឈមនឹងអំពើហិង្សា ការឃាយី និងការគំរាមកំហែងដោយសារការងាររបស់ពួកគេ៕

## ៤. ឧបសម្ព័ន្ធ

ឯកសារចេញផ្សាយសំខាន់ៗរបស់ ម.ស.ម.ក រួមមាន ៖

- របាយការណ៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជាការសង្កេតការណ៍នៅសាលាឧទ្ធរណ៍របាយការណ៍ប្រចាំឆ្នាំ (ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០)។

--- ចប់ ---